# ផលប៉ះពាល់បារីអេឡិចត្រូនិក លើសុខភាព

## (១) តើអ្វីទៅជាបារីអេឡិចត្រូនិក ?

- ជាឧបករណ៍ដែលបង្កើតឱ្យមានជាចំហាយ ឬ ផ្សែង ដោយកំដៅវត្ថុរាវដែលជាធម្មតា គឺជាសារធាតុ នីកូទីន ហើយវាមាននៅក្នុង បារី និងផលិតផលថ្នាំជក់ផ្សេងទៀត។
- ជាទូទៅ បារីអេឡិចត្រូនិក មានទម្រង់ និងទំហំ ផ្សេងៗគ្នា ដែលមានផ្នែកផ្ទុកអគ្គិសនី ផ្នែកដុតកំដៅ និងផ្នែកវត្ថុរាវ។ បារីអេឡិចត្រូនិកខ្លះ មានរូបរាង ដូចបារីធម្មតា ឧបករណ៍អង្គចងចាំ (USB Sticks) ឬ ខ្សៀរ។
- បារីអេឡិចត្រូនិកមានឈ្មោះហៅជាច្រើន ដូចជា E-cigs, E-hookahs, Mods, Vape Pens, Vapes, Tank System and ENDS (Electronic Nicotine Delivery System)។
- វត្ថុរាវដែលមាននៅក្នុង បារីអេឡិចត្រូនិក អាចជាសារធាតុផ្សេងទៀតដែលមិនមែនជា នីកូទីន ផងដែរ។

### ផ្នែកផ្សេងៗនៃបារីអេឡិចត្រូនិក




### ទម្រង់ផ្សេងៗនៃបារីអេឡិចត្រូនិក




## (២) តើនៅក្នុងចំហាយផ្សែងនៃ បារីអេឡិចត្រូនិក មានសារធាតុអ្វីខ្លះ ?




- មានសារធាតុនីកូទីនដែលជាសារធាតុញៀន
- មានសារធាតុតូចៗដែលអាចស្រូបចូលទៅក្នុងសួត
- មានសារជាតិ ឌីអាសេទីល (Diacetyl) ដែលជាសារធាតុបណ្តាលឱ្យមានជំងឺសួត
- មានសារធាតុសរីរាង្គដែលងាយហើរ
- មានសារធាតុគីមីដែលអាចបណ្តាលឱ្យកើតជំងឺមហារីក
- មានក្រុមលោហៈធ្ងន់ ដូចជា នីកែល សំណប៉ាហាំង និងសំណ។

យោងសេចក្តីណែនាំលេខ០០១/១៤ ស.ណ.ន អ.ជ.ប.គ.ញ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពីការចាត់វិធានការ បង្ការ បញ្ឈប់ការប្រើប្រាស់ ការធ្វើអាជីវកម្ម និងការនាំចូលផលិតផលស៊ីហ្សា និងបារីអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ផលប៉ះពាល់បារីអេឡិចត្រូនិក លើសុខភាព

## (៣) តើបារីអេឡិចត្រូនិក អាចបណ្តាលឱ្យមានផលប៉ះពាល់សុខភាពអ្វីខ្លះ ?





- សារធាតុនីកូទីនបណ្តាលឱ្យមានភាពញៀនខ្លាំង
- សារធាតុនីកូទីនបណ្តាលឱ្យមានភាពពុលដល់ទារកក្នុងផ្ទៃ
- សារធាតុនីកូទីនបណ្តាលឱ្យមានហានិភ័យដល់ការលូតលាស់ខួរក្បាលរបស់កុមារ ឬក្មេងជំទង់
- សារធាតុនីកូទីនបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកមានផ្ទៃពោះ និងការលូតលាស់ទារកក្នុងផ្ទៃ
- ក្រៅពីសារធាតុនីកូទីន បារីអេឡិចត្រូនិក មានសារធាតុគីមីផ្សេងទៀតដែលអាច បណ្តាលឱ្យមានជំងឺមហារីក
- ចំពោះអ្នកដែលនៅជុំវិញ អ្នកដែលកំពុងជក់បារីអេឡិចត្រូនិក ក៏មានការទទួលរងផលប៉ះពាល់សុខភាពផងដែរ។

.................................................

យោងសេចក្តីណែនាំលេខ០០១/១៨ ស.ណ.ន អ.ជ.ប.គ.ញ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពីការចាត់វិធានការ បង្ការ បញ្ឈប់ការប្រើប្រាស់ ការធ្វើអាជីវកម្ម និងការនាំចូលផលិតផលស៊ីហ្សា និងបារីអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។